**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ អង្គារ ៨ រោច ខែ អស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០២២*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីជំនួបសម្តែងការគួរសមរវាង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាមួយលោកបណ្ឌិត LEE JOONG KEUN ប្រធាន ប៊ូ យ៉ុង គ្រុប នៃសាធារណរដ្ឋកូរ៉េ

នៅព្រឹកថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០២២, នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបសម្តែងការគួរសមជាមួយលោកបណ្ឌិត **LEE JOONG KEUN** ប្រធាន **ប៊ូ យ៉ុង** គ្រុប នៃសាធារណរដ្ឋកូរ៉េ ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅ និងបានវាយតម្លៃខ្ពស់ចំពោះក្រុមហ៊ុន **ប៊ូ យ៉ុង** ខ្មែរ (ក្រុមហ៊ុន ប៊ូ យ៉ុង ខ្មែរ II ខូអិលធីឌី) ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍវិស័យសង្គម-សេដ្ឋកិច្ចកម្ពុជា តាមរយៈការចូលរួមអភិវឌ្ឍវិស័យហិរញ្ញវត្ថុ អចលនទ្រព្យ ក៏ដូចជាចូលរួមសកម្មភាពមនុស្សធម៌ជាច្រើនផ្សេងទៀតនៅកម្ពុជា ។ ភ្ជាប់ជាមួយគ្នានេះ, ក្នុងបរិការនៃការប្រយុទ្ធប្រឆាំងជាមួយការរីករាតត្បាតនៃជំងឺកូវីដ ១៩, **ឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានគូសបញ្ជាក់ពីការរីកចម្រើន និងសារៈសំខាន់នៃវិស័យ digital ក៏ដូចជា FinTech នៅប្រទេសកម្ពុជា និងស្នើឱ្យក្រុមហ៊ុនពិនិត្យលទ្ធភាពលើការវិនិយោគបន្ថែម និងផ្តល់ការគាំទ្រដល់ការអភិវឌ្ឍវិស័យ FinTech នៅប្រទេសកម្ពុជា ជាដើមផងដែរ ។

លោកបណ្ឌិត **LEE JOONG KEUN** ប្រធាន **ប៊ូ យ៉ុង** គ្រុប នៃសាធារណរដ្ឋកូរ៉េ ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ដែលបានផ្តល់ការអនុញ្ញាតដល់គណៈប្រតិភូនៃ **ប៊ូ យ៉ុង** គ្រុប បានចូលជួបសម្តែងការគួរសម ។ លោកបានបន្ថែមថា លោកបានទទួលស្គាល់តួនាទីស្នូលយ៉ាងចម្បងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិសេស ផ្នែកពន្ធដារ, ដែលកម្ពុជា ក៏ដូចជាកូរ៉េសាធារណៈរដ្ឋដែរ, ដើរតួជាសសរស្តម្ភមួយ គាំទ្រដល់សេដ្ឋកិច្ចជាតិ ។ ក្នុងន័យនេះ, លោកបានបន្ថែមថា **ប៊ូ យ៉ុង** គ្រុប នៃសាធារណរដ្ឋកូរ៉េ នឹងពិនិត្យលទ្ធភាព ក្នុងការបើកសកលវិទ្យាល័យ ដែលផ្តោតទៅលើវិស័យពន្ធដារ និង Fintech នៅកម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដល់ក្រុមហ៊ុន **ប៊ូ យ៉ុង** គ្រុប និងសង្ឃឹមថាក្រុមហ៊ុន នឹងបន្តពង្រីកការវិនិយោគរបស់ខ្លួនលើការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំង បន្តផ្តល់ការគាំទ្រ និងសហការផ្សេងៗទៀតចំពោះក្រុមហ៊ុន នៅកម្ពុជា ។